ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦
## ថ្ងៃចន្ទ ទី៣០ ខែមីនា ឆ្នាំ២០២០

អគ្គលេខាធិការដ្ឋានរដ្ឋសភាសូមជម្រាបជូន សាធារណជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ៨:០០នាទី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានបើកសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** ដោយមានវត្តមានសមាជិក សមាជិការដ្ឋសភាពេលផ្តើមសម័យប្រជុំចំនួន ១២១រូប។

របៀបវារៈសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ នាឱកាសនេះ មានតែមួយ គឺ **ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល**។

មុនចូលដល់របៀបវារៈ អង្គប្រជុំរដ្ឋសភាបានអនុម័តសមាសភាពលេខាធិការចំនួន ៣រូប សម្រាប់សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ដែលមាន៖

១- ឯកឧត្តម **ឈឹម ម៉ា**

២- លោកជំទាវ **គីម សុវណ្ណា**

៣- ឯកឧត្តម **លី ឆេង**

អង្គសភាបានបោះឆ្នោតគាំទ្រ ដោយសំឡេងព្រម ចំនួន ១២០សំឡេង នៃសមាជិករដ្ឋសភាទាំងមូល ក្នុងការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល ដូចខាងក្រោម៖

**១- តែងតាំងទេសរដ្ឋមន្ត្រី**

១- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ជា ទេសរដ្ឋមន្ត្រី

២- ឯកឧត្តម **ហ៊ឹម ឆែម** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៣- ឯកឧត្តម **អង្គ វង្សវឌ្ឍានា** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៤- ឯកឧត្តម **ត្រាំ អ៊ីវតឹក** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

៥- ឯកឧត្តម **ពៅ ប៊ុនធិន** ជា ទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)

**២- កែសម្រួល និងតែងតាំងសមាសភាពរដ្ឋមន្ត្រី**

១- ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

២- ឯកឧត្តម **កើត រិទ្ធ** ជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៣- ឯកឧត្តម **ជា វ៉ាន់ដេត** ជា រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៤- ឯកឧត្តម **ឈិត សុខុន** ជា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

៥- ឯកឧត្តម **វ៉ាំ សុខា** ជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ បានបិទសម័យប្រជុំនៅវេលាម៉ោង ៨:៥៣នាទី នាថ្ងៃខែឆ្នាំដដែល។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមសាធារណជនជ្រាបជាព័ត៌មាន៕

ថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**